**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

តុលាការកំពូល និងមហាអយ្យការ
អមតុលាការកំពូល
លេខ ២៣០/០៦/តកក

# ប្រធានតុលាការកំពូល

**ជម្រាបមក**

លោក លោកស្រី ជាចៅក្រម

ព្រះរាជអាជ្ញា ព្រះរាជអាជ្ញារងទាំងអស់

*សូមជ្រាប។*

**កម្មវត្ថុ:** អំពីការសម្រេចមុនអង្គសេចក្តីក្នុងរឿងព្រហ្មទណ្ឌ

ខ្ញុំសូមជម្រាបលោក-លោកស្រីថា កន្លងមកតុលាការកំពូល សង្កេតឃើញថា សេចក្តីសម្រេចមុនអង្គសេចក្តីក្នុងរឿងព្រហ្មទណ្ឌរបស់តុលាការខេត្ត-ក្រុង និងអយ្យការអមតុលាការខេត្ត-ក្រុង មួយចំនួនដូចជាដីកាតម្កល់រឿងទុកមិនចាត់ការ ដីកាឱ្យនៅក្រៅឃុំជាបណ្តោះអាសន្ន ពិសេសដីកាលើកលែងចោទប្រកាន់ច្រើនធ្វើឡើងដោយពុំមានសំអាងហេតុត្រឹមត្រូវ ឬ ពុំមានលំអាងហេតុណាមួយទាល់តែសោះ ។

ខ្ញុំសូមរំលឹកលោក-លោកស្រីថា តាមគោលការណ៍ច្បាប់ រាល់សេចក្តីសម្រេចទាំងអស់ត្រូវតែមានសំអាងហេតុ ។ សំអាងហេតុត្រូវតែច្បាស់លាស់ និងគ្រប់ចំណុចសំខាន់ៗបញ្ជាក់នូវគំនិតរបស់ចៅក្រមដែលមិនអាចឱ្យមានការភ័ន្តច្រឡំនោះឡើយ ។

អាស្រ័យហេតុនេះ ខ្ញុំសូមលោក-លោកស្រី ជាចៅក្រម ជាព្រះរាជអាជ្ញា ព្រះរាជអាជ្ញារងទាំងអស់យកចិត្តទុកដាក់ឱ្យបានហ្មត់ចត់ក្នុងការសរសេរសំអាងហេតុដោយលើកបទបញ្ញត្តិច្បាប់ជាធរមានជាបង្អែក និងសំណូមពរដល់លោកប្រធានតុលាការត្រួតពិនិត្យឱ្យបានដិតដល់នូវដីកាទាំងនោះមុននឹងបញ្ជូនចេញ ។

សូមលោក-លោកស្រី ទទួលនូវការរាប់អានដ៏ស្មោះស្ម័គ្រអំពីខ្ញុំ ។

ភ្នំពេញ ថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០០៦

**ឌិត មុន្ទី**